## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

និបាលកម្ពុជា

៧៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# សៀវភៅស្នាក់នៅ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជ.ស-រកត-០៨៩៧-១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៧

## សំរេច

**មាត្រា១** .- ត្រូវបានបង្កើតសៀវភៅស្នាក់នៅ ដូចមានគំរូចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២** .-សៀវភៅស្នាក់នៅ ជាសៀវភៅសំរាប់ប្រើប្រាស់ជាវិធានការនគរបាល ដើម្បីស្រង់ពត៌មាន អំពីចំនួនមនុស្សដែលស្នាក់នៅក្នុងគេហដ្ឋាននីមួយៗ ។

សៀវភៅនេះ មិនសំរាប់បញ្ជាក់អំពីញាតិភាព ឬ សញ្ជាតិខ្មែរ នៃមនុស្សដែលមានឈ្មោះចុះក្នុងបញ្ជីសៀវភៅនេះឡើយ ។

**មាត្រា៣** .-ជនគ្រប់រូបដែលជាអ្នកទទួលខុសត្រូវចម្បង នៃគេហដ្ឋាននីមួយៗ ទោះជាជននោះជាម្ចាស់ផ្ទះក្តី ឬ ជាអ្នកជួលក្តី មានកាតព្វកិច្ច ចុះក្នុងសៀវភៅស្នាក់នៅ នូវឈ្មោះមនុស្សគ្រប់រូប ដែលរស់នៅជាប់លាប់ជាមួយខ្លួន ។

**មាត្រា៤** .-ការគ្រប់គ្រង និង ការចុះឈ្មោះសៀវភៅស្នាក់នៅ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៥** .-បែបបទនៃការចុះឈ្មោះ ក្នុងសៀវភៅស្នាក់នៅ ត្រូវកំណត់ដោយប្រកាសដោយក្រសួងមហាផ្ទៃ ។

**មាត្រា៦** -អ្នកទទួលខុសត្រូវចម្បងណា ដែលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមមាត្រា៣ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលយ៉ាងយូរបីខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ត្រូវពិន័យជាប្រាក់៥០.០០០៛០០ ( ប្រាំម៉ឺនរៀល ) និង តម្រូវអោយជននោះចុះឈ្មោះខ្លួន និងសមាជិកខ្លួនក្នុងសៀវភៅស្នាក់នៅ ចាប់ពីថ្ងៃដែលពិន័យជាប្រាក់ខាងលើនេះ ។

**មាត្រា៧** .-អាជ្ញាធរមានសមត្ថកិច្ចណា ដែលអនុវត្តភារកិច្ចផ្ទុយពីបទបញ្ញត្តិ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា៨** .- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩** .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

**អ៊ុង ហួត** **ហ៊ុន សែន**

បានជំរាបជូន

នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ខេង** **យូ ហុកគ្រី**

<u>ចម្លងជូន</u> :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី២
- ដូចមាត្រា៩
- ឯកសារ- កាលប្បវត្តិ